# ធម្មកថា

## របស់ព្រះតេជព្រះគុណបណ្ឌិតហុក-សាវណ្ណ
## អំពីពាក្យរបស់ព្រះពុទ្ធមិនឲ្យមនុស្សសត្វបៀតបៀនគ្នា
## ដោយយកខ្លួនជាគ្រឿងឧបមា

web site: hoksavann.org

ថ្ងៃទី១ មករា ២០០៦

គាថាមួយបទនៅក្នុងគម្ពីរព្រះពុទ្ធសាសនាពោលថា សព្វេ តសន្តិ ទណ្ឌស្ស សព្វេសំ ជីវិតំ បិយំ អត្តានំ ឧបមំ កត្វា ន ហនេយ្យ ន ឃាតយេ ប្រែថា សត្វទាំងឡាយសុទ្ធតែតក់ស្លុតចំពោះអាជ្ញាគ្រប់ៗគ្នាទាំងអស់ សត្វទាំងឡាយសុទ្ធតែស្រឡាញ់ជីវិតគ្រប់ៗគ្នាទាំងអស់ ដូច្នេះបុគ្គលគប្បីធ្វើខ្លួនជាគ្រឿងឧបមា ហើយមិនគួរវាយប្រហារដោយខ្លួនឯង មិនគួរប្រើអ្នកដទៃឲ្យវាយប្រហារនូវសត្វដទៃឡើយ ។

ពាក្យថាសត្វទាំងឡាយ សុទ្ធតែតក់ស្លុតចំពោះអាជ្ញាគ្រប់ៗគ្នាទាំងអស់ បានសេចក្តីថា ទាំងមនុស្សទាំងសត្វតិរច្ឆានដែលមានជីវិត សុទ្ធតែមានការភ័យខ្លាចចំពោះអាជ្ញាវាយដោយដំបង ចាក់ដោយកាំបិត បាញ់ដោយកាំភ្លើងជាដើមគ្រប់ៗគ្នា បានសេចក្តីថា សត្វទាំងឡាយសុទ្ធតែចង់រស់នៅ ពុំចង់ស្លាប់ ចង់មានអាយុវែង មិនចង់មានរោគាព្យាធិ ទោះបីជីវិតស្ថិតនៅក្នុងវ័យជរានិងអ្នកពិការ ក៏សុទ្ធតែចង់រស់មិនចង់ស្លាប់ គឺមានចិត្តជាប់នឹងជីវិតរបស់ខ្លួនជានិច្ច ។ ពាក្យថាដូច្នេះ បុគ្គលគប្បីធ្វើខ្លួនជាគ្រឿងឧបមា ហើយមិនគួរវាយប្រហារដោយខ្លួនឯង មិនគួរប្រើអ្នកដទៃ ឲ្យវាយប្រហារនូវសត្វដទៃ បានសេចក្តីថា មុននឹងបៀតបៀនមនុស្សសត្វដទៃត្រូវប្រៀបធៀបមកខ្លួនថា ស្រឡាញ់ជីវិតខ្លួន មិនចង់ឲ្យអ្នកដទៃវាយប្រហារ មិនចង់ឲ្យអ្នកដទៃសម្លាប់ជាដើម មនុស្សសត្វទាំងឡាយដទៃទៀត ក៏មានបំណងនេះដូចគ្នា ដូច្នេះពុំគួរបៀតបៀនគ្នា ដោយមធ្យោបាយណាមួយឡើយ ។ ព្រះពុទ្ធសាសនាសំដែងថា មនុស្សកើតមកមានអាយុខ្លីឆាប់ស្លាប់ទៅវិញ ព្រោះកាលពីជាតិមុន បានសម្លាប់សត្វបំបាត់ជីវិតគេ ។ កើតមកមានរោគច្រើន មានជម្ងឺប្រចាំកាយ ព្រោះកាលពីជាតិមុន បៀតបៀនមនុស្ស ធ្វើឲ្យគេរងទុក្ខវេទនាតាមផ្លូវកាយឬតាមផ្លូវចិត្ត ។ ក្រុមគ្រួសារម្តាយឪពុកប្តីប្រពន្ធកូនចៅ ឆាប់ព្រាត់ប្រាស់បែកបាក់គ្នា មកពីជាតិមុន

នោះ ពង្រាត់ពង្រះសត្វ ធ្វើឲ្យមេបាកូនចៅគេបែកបាក់គ្នា ។

បើពុទ្ធសាសនិកជនខ្មែរគ្រប់ឋានៈគោរពតាមពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធដូចពោលមកនេះ នោះការបៀតបៀនគ្នាពុំមានឡើយ ។ សង្គមមួយឬប្រទេសមួយដែលពុំមានការបៀតបៀនគ្នា សង្គមនោះនឹងមានសុខស្ងប់ ។ ត្រង់ព្រះពុទ្ធមិនឲ្យមនុស្សសត្វបៀតបៀនគ្នានេះហើយ ដែលទុកជាមូលដ្ឋាននៃការគោរពសិទ្ធិមនុស្ស ។ ប្រជាពលរដ្ឋខ្មែរមានភ័ព្វសំណាងណាស់ ដោយបានទទួលកាន់យកព្រះធម៌របស់ព្រះពុទ្ធ ដែលជាធម៌ដ៏បរិសុទ្ធ សំរាប់ញ៉ាំងអ្នកប្រតិបត្តិតាមទទួលសេចក្តីសុខចំរើនក្នុងជីវភាពប្រចាំថ្ងៃនិងជីវិតអនាគត ។ ព្រះធម៌ជាច្បាប់ព្រះពុទ្ធសាសនានេះ ជាជំនួយសំខាន់ណាស់សំរាប់ផ្លូវអាណាចក្ររបស់ប្រទេសកម្ពុជា បានជាមានពាក្យខ្មែរថា ផ្លូវពុទ្ធចក្រនិងអាណាចក្រត្រូវដើរទៅជាមួយគ្នា ទើបធ្វើឲ្យប្រទេសកម្ពុជាបានសុខសន្តិភាព ។៚

❑ ❑

❑